# អនុក្រឹត្យចាស់

## ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់

## អគ្គលេខាធិការដ្ឋាន នៃអ.ជ.ប.គ.ញ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់

## អគ្គលេខាធិការដ្ឋាន នៃ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- តាមសំណើរបស់ អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

សំរេច

## ជំពូក ១

## បទបញ្ញត្តិទូទៅ

មាត្រា១ : អនុក្រិត្យនេះ កំណត់តួនាទី មុខងារ សមត្ថកិច្ច និង រៀបចំ អង្គភាពនានា របស់ អគ្គលេខាធិការដ្ឋាន នៃ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## ជំពូក ២

## តួនាទី មុខងារ សមត្ថកិច្ច និង រចនាសម្ព័ន្ធ

មាត្រា២ : អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានតួនាទីដ៏សំខាន់ក្នុងការប្រមូលពត៌មាន និង ក្នុងប្រតិបត្តិការ ប្រឆាំងនិង ការជួញដូរ ការផលិត និងការប្រើជំនួញ គ្រឿងញៀន និងសំរបសំរួល រាល់សកម្មភាព ត្រួតពិនិត្យគ្រឿងញៀនរបស់ទីភ្នាក់ងារប្រតិបត្តិដទៃទៀត ដើម្បីធានាអោយបាននូវប្រសិទ្ធិភាព និង សុវត្ថិភាព នៃការបង្ក្រាបគ្រឿងញៀននៅកម្ពុជា ។ នៅក្នុងតួនាទីនេះ អគ្គលេខាធិការដ្ឋានមានមុខងារសំខាន់ៗ ដូចតទៅ ៖

១- រៀបចំ ជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង រាជរដ្ឋាភិបាល នូវ យុទ្ធសាស្ត្រ និង ផែនការ សកម្មភាពបង្ក្រាប ការជួញដូរ ការផលិត និងការជួញ គ្រឿងញៀន ដោយសំរបសំរួលអោយមាន ការចូលរួមជាសកម្ម របស់ក្រសួង និង អង្គការពាក់ព័ន្ធ ដទៃទៀត ។

២- រាំចរងការអនុវត្តន៍នយោបាយ និង សេចក្តីសំរេច របស់រាជរដ្ឋាភិបាល និង អាជ្ញាធរជាតិប្រយុទ្ធប្រឆាំង គ្រឿងញៀន ។

៣- ជំរុញ និង សំរបសំរួល នូវវិធានការ ដែលចាត់ឡើងដោយក្រសួងពាក់ព័ន្ធ ។

៤- ទំនាក់ទំនងជាមួយនិងរដ្ឋាភិបាលបរទេសនិងអង្គការអន្តរជាតិនានា ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

មាត្រា៣ : នៅក្នុងក្របខ័ណ្ឌនៃការបំពេញនូវតួនាទី និង មុខងាររបស់ខ្លួនខាងលើនេះ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវមានសមត្ថកិច្ច ដូចតទៅ ៖

១- រៀបចំ និង ចូលរួមក្នុងកិច្ចពិភាក្សា របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

២- តាក់តែងនូវ ពង្រាងច្បាប់ ក្រិត្យអនុវត្ត និង បទបញ្ញត្តិ ក្នុងវិស័យ បង្ការ និង បង្ក្រាប ការជួញដូរ ការផលិត ការប្រើជំនួញគ្រឿងញៀន និងការទាញផលចំណេញពីគ្រឿងញៀន ដោយសហការជាមួយនិង ក្រសួង និង អង្គការពាក់ព័ន្ធ ។

៣- ជំរុញ និង សំរបសំរួល ការប្រមូលពត៌មាន និង ស្ថិតិ ដែលកំណត់នៅក្នុងអនុសញ្ញាអន្តរជាតិ និង ការបញ្ជូនពត៌មាន និង ស្ថិតិទាំងនោះ ទៅអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ។

៤- បញ្ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវអាស័យដ្ឋាន របស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បី អនុវត្ត បទបញ្ញត្តិ នៃអនុសញ្ញា ។

៥- រៀបចំនីតិវិធី ស្តីពីសុវត្ថភាព នៃការទុកដាក់ និងការកំទេចចោល គ្រឿងញៀន ដែលចាប់បាន ដោយ

សហការជាមួយ ក្រសួង និង អង្គការពាក់ព័ន្ធដទៃទៀត ។

៦- ត្រួតពិនិត្យ និង បង្រ្កាប ការដាំដុះ ការផលិត ការនាំចូល ការនាំចេញ ការចែកចាយ ការឆ្លងកាត់ ឬ ការស៊ុចត គ្រឿងញៀន ឱសថ និង ថ្នាំស្របច្បាប់កំណត់ដោយក្រសួងសុខាភិបាល ដែលមាន សារធាតុគ្រឿងញៀន ដោយសហការ ជាមួយនិង ក្រសួង និង អង្គការពាក់ព័ន្ធ ដទៃទៀត ។

៧- ដាក់អោយដំណើរការ នូវប្រព័ន្ធមួយសំរាប់ពិនិត្យតាមដាន និង វិភាគការប្រើប្រាស់គ្រឿងញៀន ដោយសហការជាមួយនិង ក្រសួង និង អង្គការពាក់ព័ន្ធដទៃទៀត ។

៨- រៀបចំ និង អនុវត្ត កម្មវិធីអប់រំ បង្ការកុំអោយមានការប្រើប្រាស់គ្រឿងញៀន ដោយសហការជាមួយនិងក្រសួង និងអង្គការពាក់ព័ន្ធដទៃទៀត ។

៩- សំរបសំរួលសកម្មភាពរបស់រដ្ឋាភិបាល ប្រឆាំងនិងការសំអាតប្រាក់ទាក់ទងនឹងគ្រឿងញៀន ។

១០- សំរបសំរួលការត្រួតពិនិត្យរបស់រាជរដ្ឋាភិបាល លើសារធាតុសំរាប់ផ្សំគ្រឿងញៀន ។

១១- រៀបចំ និង អនុវត្ត នីតិវិធី និង កម្មវិធី សំរាប់ទទួលព្យាបាល និងជួយអ្នកញៀនអោយបានមករស់នៅក្នុងភាពធម្មតាវិញ ដោយសហការជាមួយនិងក្រសួង និងអង្គការពាក់ព័ន្ធដទៃទៀត ។

មាត្រា៤ : អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានរចនាសម្ព័ន្ធដូចតទៅ :

១- ខុទ្ទកាល័យអគ្គលេខាធិការ

២- អធិការដ្ឋាន

៣- មន្ទីរពិសោធន៍គ្រឿងញៀន

៤- នាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ

៥- នាយកដ្ឋាន ផែនការ និង បណ្តុះបណ្តាល

៦- នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ

៧- នាយកដ្ឋាន អនុវត្តច្បាប់

៨- នាយកដ្ឋាន នីតិកម្ម អប់រំ និង បង្ការការពារ

៩- នាយកដ្ឋាន ស្រាវជ្រាវ និង ត្រួតពិនិត្យ

១០- អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

អង្គការលេខរបស់ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា៥ : អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវបានដឹកនាំ និង គ្រប់គ្រងដោយ អគ្គលេខាធិការមួយរូប ដែលមាន អគ្គលេខាធិការរងបីរូប ជាជំនួយការ ។ លើសពីនេះ អគ្គលេខាធិការ មានភារកិច្ចដឹកនាំនិងគ្រប់គ្រងដោយផ្ទាល់ អធិការដ្ឋាន មន្ទីរពិសោធន៍គ្រឿងញៀន និង នាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ ។

អគ្គលេខាធិការរងម្នាក់ ត្រូវទទួលបន្ទុកដឹកនាំ និង គ្រប់គ្រងការអនុវត្តន៍ការងាររបស់នាយកដ្ឋានអនុវត្តច្បាប់ ។

អគ្គលេខាធិការរងម្នាក់ ត្រូវទទួលបន្ទុកដឹកនាំ និង គ្រប់គ្រងការអនុវត្តន៍ការងារ របស់ នាយកដ្ឋាន ពីរ ៖

ក- នាយកដ្ឋាន ផែនការ និង បណ្តុះបណ្តាល

ខ- នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ

អគ្គលេខាធិការរងម្នាក់ទៀត ត្រូវទទួលបន្ទុកដឹកនាំ និង គ្រប់គ្រងការអនុវត្តន៍ការងារ របស់ នាយកដ្ឋាន ពីរ ៖

ក- នាយកដ្ឋាន នីតិកម្ម អប់រំ និង បង្ការការពារ

ខ- នាយកដ្ឋាន ស្រាវជ្រាវ និង ត្រួតពិនិត្យ

**មាត្រា៦ ៖** អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានសិទ្ធិធ្វើត្រាប្រើប្រាស់តាមសេចក្តីត្រូវការរបស់ខ្លួន ។

អគ្គលេខាធិការមានសិទ្ធិធ្វើប្រកាសតែងតាំងឬដកចេញពីតំណែង នូវ មន្ត្រីបុគ្គលិករបស់ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិ ចាប់ពី ថ្នាក់អនុប្រធាននាយកដ្ឋានចុះក្រោម ។

## ជំពូក ៣

## នាយកដ្ឋាន

**មាត្រា៧ ៖** នាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ មានភារៈកិច្ច ដូចតទៅ ៖

ក- សំរបសំរួល ផ្នែករដ្ឋបាល រាល់សកម្មភាពរបស់អគ្គលេខាធិការដ្ឋាន ។

ខ- គ្រប់គ្រង និង ចរាចរ ឯកសាររដ្ឋបាលផ្សេងៗរបស់ អគ្គលេខាធិការដ្ឋាន ។

គ- ធានាប្រសិទ្ធិភាព និង សុវត្ថិភាព រដ្ឋបាល របស់ អគ្គលេខាធិការដ្ឋាន ។

ឃ- សរុប និង ធ្វើរបាយការណ៍ការងារ និង សកម្មភាពផ្សេងៗរបស់ អគ្គលេខាធិការដ្ឋាន ។

ង- គ្រប់គ្រងផ្នែករដ្ឋបាល និង ហិរញ្ញវត្ថុ មន្ត្រីបុគ្គលិក របស់ អគ្គលេខាធិការដ្ឋាន ។

ច- លើក និង អនុវត្ត គំរោងថវិកាប្រចាំឆ្នាំ របស់ អគ្គលេខាធិការដ្ឋាន ។

ឆ- ប្រមូលផ្តុំ ចំណូល និង ចំណាយ របស់ អគ្គលេខាធិការដ្ឋាន ។

ជ- តាមដាន និង រំលឹក ការអនុវត្តន៍ថវិកា និង ការគ្រប់គ្រងគណនី របស់ អគ្គលេខាធិការដ្ឋាន ។

ឈ- ប្រមូលផ្តុំតំរូវការ ធ្វើកម្មវិធីចំណាយ អោយបានសមស្រប ។

ញ- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សម្ភារៈ និង ធ្វើបញ្ជីសារពើភណ្ឌ ។

ដ- ទទួល និង បែងចែក បរិក្ខារ ជូនដល់ គ្រប់អង្គភាព ទៅតាមកម្មវិធីចំណាយ ។

ឋ- រៀបចំ និង សំរួល កិច្ចប្រជុំ និង ការពិភាក្សាដេញដោល របស់ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

នាយកដ្ឋាន ត្រូវបានដឹកនាំ និង គ្រប់គ្រង ដោយ ប្រធាននាយកដ្ឋានមួយរូប និង មាន អនុប្រធាននាយកដ្ឋាន

ជាជំនួយការ តាមការចាំបាច់ ។

មាត្រា៨ ៖ នាយកដ្ឋាន ផែនការ និង បណ្តុះបណ្តាល មានភារៈកិច្ច ដូចតទៅ ៖

ក- រៀបចំយុទ្ធសាស្ត្រ និងលើកផែនការគោល ក្នុងការបង្ក្រាប ការដាំដុះ ការផលិត និងការជួញដូរ គ្រឿងញៀន ការនាំចេញនិងនាំចូលគ្រឿងញៀន និង ក្នុងការលុបបំបាត់រាល់សកម្មភាពទាញផលចំណេញ ពីគ្រឿងញៀន ដោយសហការជាមួយ ក្រសួង និង អង្គការពាក់ព័ន្ធដទៃទៀត ។

ខ- រៀបចំគំរោងសកម្មភាព ដើម្បីអនុវត្ត បទបញ្ញត្តិទាំងឡាយនៃអនុសញ្ញាអន្តរជាតិ ស្តីពីគ្រឿងញៀន ឆ្នាំ១៩៦១ ឆ្នាំ១៩៧១ និង ឆ្នាំ១៩៨៨ ។

គ- ពិនិត្យតាមដានការអនុវត្តន៍នយោបាយនិងសេចក្តីសំរេចរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំង គ្រឿងញៀន ។

ឃ- រៀបចំ និងអនុវត្ត នយោបាយមួយ ស្តីពីការបណ្តុះបណ្តាល មន្ត្រីបុគ្គលិក របស់ អគ្គលេខាធិការដ្ឋាន ។

នាយកដ្ឋាន ត្រូវបានដឹកនាំ និង គ្រប់គ្រង ដោយ ប្រធាននាយកដ្ឋានមួយរូប និង មាន អនុប្រធាននាយកដ្ឋាន ជាជំនួយការ តាមការចាំបាច់ ។

មាត្រា៩ ៖ នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ មានភារៈកិច្ច ដូចតទៅ ៖

ក- ទំនាក់ទំនងជាមួយនឹង រដ្ឋាភិបាលបរទេស និង អង្គការអនុតំបន់ និង អន្តរជាតិ នានា ។

ខ- បញ្ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវអាស័យដ្ឋាន របស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីអនុវត្ត បទបញ្ញត្តិ នៃអនុសញ្ញា ។

គ- បញ្ជូនពត៌មាននិងស្ថិតិដែលកំណត់នៅក្នុងអនុសញ្ញាអន្តរជាតិទៅអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ។

ឃ- ចូលរួម ក្នុង សកម្មភាពអនុតំបន់នានា ឬ អន្តរជាតិ ។

នាយកដ្ឋាន ត្រូវបានដឹកនាំ និង គ្រប់គ្រង ដោយ ប្រធាននាយកដ្ឋានមួយរូប និង មាន អនុប្រធាននាយកដ្ឋាន ជាជំនួយការ តាមការចាំបាច់ ។

មាត្រា១០ ៖ នាយកដ្ឋាន អនុវត្តច្បាប់ មានភារៈកិច្ច ដូចតទៅ ៖

ក- ស៊ើបអង្កេត ប្រមូលពត៌មាន ពាក់ព័ន្ធនឹងគ្រឿងញៀន ដោយសហការជាមួយនឹង ក្រសួង និង អង្គការពាក់ព័ន្ធ ដទៃទៀត ។

ខ- ត្រួតពិនិត្យ និង បង្ក្រាប ការដាំដុះ ការផលិត ការនាំចូល ការនាំចេញ ការចែកចាយ ការឆ្លងកាត់ ឬ ការស៊ុចត គ្រឿងញៀន ឱសថ និង ថ្នាំស្របច្បាប់កំណត់ដោយក្រសួងសុខាភិបាល ដែលមាន សារធាតុគ្រឿងញៀន ដោយ សហការជាមួយនឹង ក្រសួង និង អង្គការពាក់ព័ន្ធ ដទៃទៀត ។

គ- រៀបចំនីតិវិធី ស្តីពីសុវត្ថិភាព នៃការទុកដាក់ និងការកំទេចចោលគ្រឿងញៀនដែលចាប់បាន ដោយសហការជាមួយ ក្រសួង និង អង្គការពាក់ព័ន្ធដទៃទៀត ។

ឃ- អនុវត្តច្បាប់គ្រឿងញៀន និង សាលក្រមតុលាការ ដែល ពាក់ព័ន្ធនឹងគ្រឿងញៀន ។

នាយកដ្ឋាន ត្រូវបានដឹកនាំ និង គ្រប់គ្រង ដោយ ប្រធាននាយកដ្ឋានមួយរូប និង មាន អនុប្រធាននាយកដ្ឋាន ជាជំនួយការ តាមការចាំបាច់ ។

មាត្រា១១ ៖ នាយកដ្ឋាន នីតិកម្ម អប់រំ និង បង្ការការពារ មានភារៈកិច្ច ដូចតទៅ ៖

ក- ជំនួយផ្លូវច្បាប់ សំរាប់សកម្មភាពទាំងអស់របស់អគ្គលេខាធិការដ្ឋាន ។

ខ- តាក់តែងនូវ ពង្រាងច្បាប់ ក្រិត្យអនុវត្ត និង បទបញ្ញត្តិ ក្នុងវិស័យ បង្ក និង បង្ក្រាប ការដាំដុះ ការផលិត ការធ្វើជំនួញគ្រឿងញៀន និងការទាញផលចំណេញពីគ្រឿងញៀន ដោយសហការជាមួយនឹងក្រសួង និង អង្គការពាក់ព័ន្ធ ។

គ- សំរបសំរួល និង ចូលរួម ក្នុងការបង្កើត និង អនុវត្ត នូវកម្មវិធីប្រឆាំងនឹងការសំអាតលុយ ។

ឃ- តាមដាន ការវិវត្តន៍ ក្របខ័ណ្ឌនីតិក្រមរបស់រដ្ឋ និង លើកសំណើកែលំអរ ច្បាប់ ក្រិត្យអនុវត្ត និង បទបញ្ញត្តិ ដែលពាក់ព័ន្ធនឹងគ្រឿងញៀន ។

ង- រៀបចំ និង អនុវត្ត កម្មវិធីអប់រំ បង្ការ និង កាត់បន្ថយ ការប្រើប្រាស់គ្រឿងញៀន នៅក្នុងប្រទេស ដោយសំរបសំរួល និង សហការអោយបានល្អ ជាមួយនឹង ក្រសួង និង អង្គការពាក់ព័ន្ធ ដទៃទៀត ។

ច- ដាក់អោយដំណើរការ នូវប្រព័ន្ធមួយ សំរាប់ពិនិត្យតាមដាន និង វិភាគការប្រើប្រាស់គ្រឿងញៀន ដោយសហការជាមួយនឹង ក្រសួង និង អង្គការពាក់ព័ន្ធដទៃទៀត ។

ឆ- រៀបចំ និង អនុវត្ត នីតិវិធី និង កម្មវិធី សំរាប់ទទួលព្យាបាល និងជួយអ្នកញៀនអោយបានមករស់នៅក្នុងភាពធម្មតាវិញ ដោយសហការជាមួយនឹងក្រសួង និងអង្គការពាក់ព័ន្ធដទៃទៀត ។

នាយកដ្ឋាន ត្រូវបានដឹកនាំ និង គ្រប់គ្រង ដោយ ប្រធាននាយកដ្ឋានមួយរូប និង មាន អនុប្រធាននាយកដ្ឋាន ជាជំនួយការ តាមការចាំបាច់ ។

មាត្រា១២ ៖ នាយកដ្ឋាន ស្រាវជ្រាវ និង ត្រួតពិនិត្យ មានភារៈកិច្ច ដូចតទៅ ៖

ក- សំរបសំរួល និង ចូលរួមកិច្ចប្រតិបត្តិការជាមួយ ក្រសួង និង អង្គការពាក់ព័ន្ធ ដទៃទៀត ក្នុងការពិនិត្យតាមដាន ការត្រួតពិនិត្យ លើឱសថ និងថ្នាំស្របច្បាប់កំណត់ដោយក្រសួងសុខាភិបាល ។

ខ- ~~សំរបសំរួល ការបង្កើតឡើង និង ការអនុវត្តន៍ នូវការត្រួតពិនិត្យសារធាតុសំរាប់ផ្សំគ្រឿងញៀន~~ ។

នាយកដ្ឋាន ត្រូវបានដឹកនាំ និង គ្រប់គ្រង ដោយ ប្រធាននាយកដ្ឋានមួយរូប និង មាន អនុប្រធាននាយកដ្ឋាន ជាជំនួយការ តាមការចាំបាច់ ។

## ជំពូក ៤

## ខុទ្ទកាល័យអគ្គលេខាធិការ

មាត្រា១៣ : ខុទ្ទកាល័យនៃអគ្គលេខាធិការ ត្រូវបានដឹកនាំដោយ នាយខុទ្ទកាល័យមួយរូប និង មាននាយរងខុទ្ទកាល័យមួយចំនួន ជាជំនួយការតាមការចាំបាច់ ។ ខុទ្ទកាល័យនៃអគ្គលេខាធិការ ត្រូវទទួលបន្ទុកការងារទាំងឡាយដែលកំណត់តាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ-បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ របស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន ។

## ជំពូក ៥

## មន្ទីរពិសោធន៍គ្រឿងញៀន

មាត្រា១៤ : មន្ទីរពិសោធន៍គ្រឿងញៀន ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ អគ្គលេខាធិការ មានភារៈកិច្ចធ្វើការស្រាវជ្រាវ គ្រឿងញៀន និង ធ្វើតេស្តថ្នាំ ដោយមានសហការជាមួយនឹងមន្ទីរពិសោធន៍ របស់ក្រសួង និង អង្គការពាក់ព័ន្ធ ដទៃទៀត។ មន្ទីរពិសោធន៍គ្រឿងញៀន មានសិទ្ធិលើកសំណើរស្តីពី ការហាមឃាត់ ការផលិត និងការធ្វើជំនួញ ឱសថនិងថ្នាំស្របច្បាប់កំណត់ដោយក្រសួងសុខាភិបាល ដែលមន្ទីរពិសោធន៍គ្រឿងញៀនស្រាវជ្រាវរកឃើញថាមាន សារធាតុគ្រឿងញៀន លើសពីកំរិតដែលបានអនុញ្ញាត្តិ ។

## ជំពូក ៦

## អធិការដ្ឋាន

មាត្រា១៥ : អធិការដ្ឋាន ត្រូវបានដឹកនាំ និង គ្រប់គ្រងដោយអធិការមួយរូប និងមានអធិការរង ជាជំនួយការ តាមការចាំបាច់ ។ អធិការដ្ឋាន មានភារៈកិច្ច ដូចតទៅ ៖

ក- ធ្វើអធិការកិច្ច ទៅលើ គ្រប់អង្គភាពក្រោមឱវាទរបស់ អគ្គលេខាធិការដ្ឋាន ។

ខ- ធ្វើរបាយការណ៍ជូនអគ្គលេខាធិការ ស្តីពីការប្រព្រឹត្តិទៅ របស់អង្គភាព ដែលបានធ្វើអធិការកិច្ចរួចហើយនោះ និងពី មធ្យោបាយកែលំអ នៃការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនោះ ។

គ- ប្រតិបត្តិភារៈកិច្ចដែល អគ្គលេខាធិការ បានប្រគល់ទុកចិត្តអោយធ្វើ ។

## ជំពូក ~~៨~~ ៧

៣ គ 15.

## អង្គភាពមូលដ្ឋានក្រោមឱវាទ

មាត្រា១៦ ៖ អគ្គលេខាធិការដ្ឋាន នៃ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មាន ការិយាល័យបង្រ្កាបគ្រឿងញៀន នៅតាមខេត្ត-ក្រុង តាមការចាំបាច់ ដើម្បីអនុវត្ត ការងារដែល អគ្គលេខាធិការដ្ឋាន ប្រគល់អោយ ។

16

មាត្រា១៧ ៖ នៅពេលដែលអគ្គលេខាធិការដ្ឋានបានដំណើរការ មន្ទីរនិងការិយាល័យខេត្តក្រុងប្រឆាំងគ្រឿងញៀន ទាំងអស់ ...

ត្រូវធ្វើសមាហរណកម្ម ទៅក្នុង អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## ជំពូក ៨

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា១៨ : អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ញាក់លាត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្នុងបណ្តាក្រសួងឬស្ថាប័ននានា របស់រាជរដ្ឋាភិបាល ។

## ជំពូក ៩

## អវសានបញ្ញត្តិ

មាត្រា១៩ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា២០ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និង អង្គភាពពាក់ព័ន្ធ នៃ រាជរដ្ឋាភិបាល ត្រូវអនុវត្តតាមអនុក្រឹត្យនេះ តាមភារៈកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែតុលា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

អ៊ឹង ហួត ហ៊ុន សែន

បានជំរាបជូន

- ឯកឧត្តមនាយករដ្ឋមន្ត្រីទី១
- សម្តេចនាយករដ្ឋមន្ត្រីទី២

អគ្គលេខាធិការនៃអាជ្ញាធរជាតិ

ប្រយុទ្ធប្រឆាំងគ្រឿងញៀន

ស៊ុំ វ៉ានិត

ចំលងជូន :

ខុទ្ទកាល័យព្រះមហាក្សត្រ

អគ្គលេខាធិការដ្ឋានរដ្ឋសភា

ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី១

ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី២

ដូចមាត្រាទី២០

រាជកិច្ច